# កិច្ចព្រមព្រៀងគ្រប់គ្រងចៃក្បាល
# រវាងសាលារៀននិងមាតាបិតា / អាណាព្យាបាល / អ្នកថែទាំ

**(Insert school details)**

ចៃក្បាលបណ្តាលឲ្យមានការបារម្ភនិងការតានតឹងចិត្តតទៅទៀតចំពោះមាតាបិតា / អាណាព្យាបាល / អ្នកថែទាំ គ្រូបង្រៀន និងកុមារខ្លះ។ ចៃក្បាលមិនមែនជាជំងឺចម្លងមេរោគទេ ប៉ុន្តែវាឆ្លងតាមរយៈការប៉ះក្បាលគ្នាជាមួយនឹងអ្នកណាមួយដែលមានចៃក្បាល។ នៅក្នុងពេលដែលមាតាបិតាជាអ្នកទទួលខុសត្រូវចំបងចំពោះការតាមរកមើលនិងព្យាបាលកំចាត់ចៃក្បាលក្តី ក៏ការត្រួតត្រានិងគ្រប់គ្រងការរាលដាលនៃចៃក្បាល គឺជាការទទួលខុសត្រូវរួមគ្នាក្នុងចំណោមអង្គភាពមួយចំនួនដែរ ដោយមានរួមទាំងក្រសួងសិក្សាអប់រំនិងហ្វឹកហ្វឺន (Department of Education and Training) ក្រសួងសេវាពលរដ្ឋ (Department of Human Services) សាលារៀននិងមាតាបិតា។ ក្រសួងសិក្សាអប់រំនិងហ្វឹកហ្វឺនទទួលខុសត្រូវចំពោះការផ្តល់ឱវាទនិងជំនួយទៅកាន់សាលា អំពីការគ្រប់គ្រងចៃក្បាល។

កិច្ចព្រមព្រៀងនេះបញ្ជាក់អំពី :

- ការទទួលខុសត្រូវរបស់ទាំងសាលារៀន និងទាំងមាតាឬបិតា / អាណាព្យាបាល / អ្នកថែទាំ;
- សារសំខាន់នៃវិធីថែទាំសុខភាពដែលរួមបញ្ចូលទាំងអស់ ដើម្បីធានាឲ្យមានដំណោះស្រាយសមរម្យនិងមានប្រសិទ្ធភាព ទៅនឹងបញ្ហាចៃក្បាល។

*ការទទួលខុសត្រូវ*

**<u>មាតាឬបិតា / អាណាព្យាបាល / អ្នកថែទាំ</u> -** ការទទួលខុសត្រូវមានរួមទាំងការ :

- ឆែកពិនិត្យជាប្រក្រតី (ជាការប្រសើរបើធ្វើម្តងក្នុងមួយអាទិត្យ) នូវសក់របស់កូនលោកអ្នក ដើម្បីរកមើលចៃឬពងចៃ ហើយឆែកពិនិត្យជាប្រក្រតីនូវសមាជិកទាំងអស់ដែលរស់នៅក្នុងផ្ទះ បន្ទាប់មកព្យាបាលកំចាត់ចៃចេញពីអ្នកទាំងនោះ បើសិនជាចាំបាច់;
- ធ្វើឲ្យប្រាកដថា កូនរបស់លោកអ្នកនឹងមិនទៅសាលារៀនដោយគ្មានការព្យាបាលកំចាត់ចៃក្បាលនោះឡើយ;
- ប្រើវិធីអនុវត្តន៍ការព្យាបាលមានសុវត្ថិភាព ដែលមិនឲ្យមានគ្រោះថ្នាក់ដល់សុខភាពរបស់កូន (សូមអានប័ណ្ណព័ត៌មាន*ការព្យាបាលនិងការគ្រប់គ្រងចៃក្បាល*ដែលភ្ជាប់ជាមួយនេះ);
- ប្រាប់សាលា បើកូនលោកអ្នកមានចៃក្បាល ហើយប្រាប់សាលានៅពេលដែលការព្យាបាលបានចាប់ផ្តើម តាមរយៈការបំពេញក្រដាស*សកម្មភាពដែលបានធ្វើឡើង*;
- ប្រាប់មាតាបិតាឬអ្នកថែទាំនៃមិត្តភក្តិរបស់កូនលោកអ្នក ដើម្បីឲ្យអ្នកទាំងនោះមានឱកាសតាមរកមើលនិងព្យាបាលកូនគេផងដែរ បើសិនជាចាំបាច់នោះ។

ខ្ញុំបានអាននិងយល់ស្របតាមការទទួលខុសត្រូវខាងលើនេះ :

**ហត្ថលេខារបស់មាតាឬបិតា / អ្នកថែទាំ / អាណាព្យាបាល : .................................. ថ្ងៃទី ........................**

**ហត្ថលេខារបស់មាតាឬបិតា / អ្នកថែទាំ / អាណាព្យាបាល : .................................. ថ្ងៃទី ........................**

**<u>សាលារៀន</u> -** ការទទួលខុសត្រូវមានរួមទាំងការ :

- ចែកចាយបទបញ្ញត្តិនិងព័ត៌មានអំពីការតាមរកមើល ព្យាបាល និង គ្រប់គ្រងចៃក្បាល ទៅឲ្យមាតាបិតា / អាណាព្យាបាល / អ្នកថែទាំ និង បុគ្គលិក ហើយនិងមានពិធីការច្បាស់លាស់ដែលអាចបើកមើលឬទទួលបាន សំរាប់កម្មវិធីឆែកពិនិត្យមើលដែលអនុវត្តដោយសាលារៀន;
- បង្កើតបទបញ្ញត្តិសាលារៀនអំពីចៃក្បាល ដែលពង្រឹងវិធីត្រឹមត្រូវច្បាស់លាស់ មិនប្រែប្រួល សំរាប់គ្រប់គ្រងការឆ្លងចៃក្បាល ដែលយល់ព្រមដោយក្រុមប្រឹក្សាសាលារៀន;
- ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមាតាបិតា ដើម្បីធ្វើការឆែកពិនិត្យរកមើលចៃក្បាល នៅពេលចុះឈ្មោះរបស់សិស្ស ដើម្បីអនុវត្តសំរាប់រយៈពេលសិក្សារបស់សិស្ស នៅឯសាលាជាក់លាក់ ហើយដើម្បីជ្រើសតាំងអ្នកមានការបណ្តុះបណ្តាល សំរាប់ឆែកពិនិត្យរកមើលចៃក្បាល ដែលយល់ព្រមដោយនាយកសាលានិងក្រុមប្រឹក្សាសាលារៀន;
- ជំរុញទឹកចិត្តអ្នកដែលទទួលការអនុញ្ញាតដោយនាយកសាលា ឧទាហរណ៍: គ្រូបង្រៀន ដើម្បីឆែករកមើលតាមការសម្លឹងមើលសក់របស់សិស្ស ពោលគឺពុំមានការប៉ះពាល់រាងកាយសិស្សទេ បើមានការសង្ស័យថាមានចៃក្បាល;
- ជំរុញទឹកចិត្តមាតាបិតា / អាណាព្យាបាល / អ្នកថែទាំ ឲ្យឆែកមើលកូនរបស់ខ្លួនជាប្រក្រតីតទៅទៀត ដើម្បីរកមើលចៃក្បាល និងផ្តល់ឥរិយាបថអាណិតនិងឱវាទប្រតិបត្តិទៅឲ្យមាតាបិតាទាំងឡាយដែលមានការលំបាកអំពីវិធានការគ្រប់គ្រង;
- ជំរុញទឹកចិត្តសិស្សឲ្យរៀនសូត្រអំពីចៃក្បាល ដើម្បីជួយដកចេញនូវស្លាកស្នាមមិនល្អ ឬ "ការធ្វើបាប"ណាមួយ ដែលពាក់ព័ន្ធនឹងបញ្ហានេះ;
- ដឹងថា ការទទួលខុសត្រូវមិនឲ្យសិស្សណាមួយមិនទៅសាលារៀន គឺស្ថិតនៅលើនាយកសាលាឬអ្នកទទួលខុសត្រូវសាលារៀន ហើយដឹងថា ការមិនឲ្យទៅរៀនគឺយោងសំដៅទៅកាន់សិស្សទាំងឡាយដែលមានចៃរស់តែប៉ុណ្ណោះ ហើយមិនយោងសំដៅទៅកាន់ពងចៃឡើយ; ហើយដឹងអំពីសេចក្តីស្នើសុំមិនឲ្យសិស្សទៅសាលារៀននៅពេលបញ្ចប់ថ្ងៃសិក្សានៅសាលា នៅពេលដែលសិស្សគួរទទួលលិខិតជូនដំណឹងមួយសំរាប់យកទៅផ្ទះ ដើម្បីប្រាប់មាតាឬបិតាថា កូនអាចមានចៃក្បាល។
- ដឹងថា មានតម្រូវការនៅក្នុង*បទបញ្ញត្តិសុខភាព (រោគឆ្លង) ឆ្នាំ 2001* សំរាប់កុមារដែលបានទទួលការព្យាបាលកំចាត់ចៃក្បាល ក្នុងការទទួលលិខិតបញ្ជាក់ថាពុំមានចៃតទៅទៀត ដែលចេញឲ្យដោយវេជ្ជបណ្ឌិត ឬ ក្រុមប្រឹក្សាសាលាក្រុង នៅពេលវិលទៅកាន់សាលារៀនវិញ;
- នៅពេលសមរម្យ និងទៅតាម សេចក្តីសំរេចចិត្តរបស់នាយកសាលា ត្រូវផ្តល់លិខិតជូនដំណឹងសភាពប្រុងជើងការមួយទៅកាន់សហគមន៍សាលា នៅពេលដែលបានរកឃើញចៃក្បាលនៅសាលារៀន;
- ជំរុញទឹកចិត្តមាតាបិតា / អាណាព្យាបាល / អ្នកថែទាំ ក្នុងការរកមើលដឹងការព្យាបាលដែលប្រើ និងថ្ងៃចាប់ផ្តើម តាមរយៈក្រដាសបំពេញ *សកម្មភាពដែលបានធ្វើឡើង*។

(insert name of school) មានការប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងចៃក្បាល តាមលក្ខណៈយល់ដឹងនិងលាក់ការសម្ងាត់។ យើងមានការប្តេជ្ញាចិត្តធ្វើតាមការទទួលខុសត្រូវខាងលើនេះ។

**ហត្ថលេខារបស់នាយកសាលា .................................. ថ្ងៃទី........................**